FARMER NOTES
ព្រឹត្តិប័ត្រព័ត៌មានកសិករ

ការចេញផ្សាយរបស់វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា
A Publication of the Cambodian Agricultural Research and Development Institute

# ដង្កូវស៊ីរូងដើមស្រូវ

## I. សេចក្តីផ្តើម

ដង្កូវស៊ីរូងដើមមានច្រើនប្រភេទនៅប្រទេសកម្ពុជាដូចជា ដង្កូវស៊ីរូងដើមពណ៌លឿង ដង្កូវស៊ីរូងដើមពណ៌ស៊ីជម្ពូ ដង្កូវស៊ីរូងដើមឆ្នូត និងដង្កូវស៊ីរូងដើមក្បាលខ្មៅ ។ ប៉ុន្តែគេប្រទះឃើញភាគច្រើន នៅក្នុងប្រទេសយើង គឺពួកដង្កូវស៊ីរូងដើមពណ៌លឿង ដង្កូវស៊ីរូងដើមក្បាលខ្មៅ និងដង្កូវស៊ីរូងដើមឆ្នូត ។

មេអំបៅដង្កូវស៊ីរូងដើម ពេលថ្ងៃលាក់ខ្លួននៅក្នុងស្មៅជិតស្រែ ឬក្នុងស្រូវ ។ ពេលយប់វាធ្វើសកម្មភាពរកស៊ី និងដោយញីឈ្មោល ហើយវាចូលចិត្តពន្លឺភ្លើង ។ វាអាចហើរបានឆ្ងាយ ជាធម្មតារហូតដល់២គម ហើយមេមួយអាចពងបានប្រហែល ២០០ ទៅ ៣០០ ពង ក្នុងរយៈពេល ៥ថ្ងៃ ។

## II. លក្ខណៈរូបរាង

មេអំបៅដង្កូវស៊ីរូងដើមពណ៌លឿងមេមានទំហំធំជាងឈ្មោល ដែលឈ្មោលមានពណ៌ត្នោតខ្ចី មានចំណុចខ្មៅតូចនៅលើស្លាបម្ខាងមួយ និងមានស្នាមអុចឆ្នូតៗចំនួន ៥ នៅគល់ស្លាប និង៨ ទៅ៩ នៅខាងចុងស្លាប ។ ចំណែកមេអំបៅញីមានពណ៌ចំបើង និងមានចំណុចខ្មៅចំកណ្តាលស្លាបម្ខាងមួយ ។

មេអំបៅដង្កូវស៊ីរូងដើមក្បាលខ្មៅ និងឆ្នូតមានភាពប្រហាក់ប្រហែលគ្នា ដោយមានពណ៌ចំបើងទៅត្នោតស្រាល និងមានចំណុចពណ៌ប្រាក់នៅលើផ្ទៃស្លាប និងចំណុចខ្មៅតូចៗនៅខាងចុងស្លាប ។


មេអំបៅដង្កូវស៊ីរូងដើម ឆ្នូត


មេអំបៅដង្កូវស៊ីរូងដើម ពណ៌លឿង


មេអំបៅដង្កូវស៊ីរូងដើម ក្បាលខ្មៅ



ពងវាមានពណ៌លឿងភ្លឺរលោងនៅរាយប៉ាយ ឬផ្តុំគ្នាជាសំបុកពី២០០ ទៅ ៣០០ នៅផ្នែកខាងលើផ្ទៃស្លឹក និងនៅស្រទាប់ស្លឹកស្រូវ ទៅតាមប្រភេទរបស់វា ។

ដង្កូវស៊ីរូងដើមពណ៌លឿងមានពណ៌លឿង ក្បាលវាពណ៌ទឹកក្រូច និងចូលស៊ីតែមួយក្នុងមួយដើម ។ ដង្កូវស៊ីរូងដើមឆ្នូតមានឆ្នូត៥តាមបណ្តោយដងខ្លួន ក្បាលវាពណ៌ត្នោត ។ ដង្កូវស៊ីរូងដើមក្បាលខ្មៅមានឆ្នូត៥តាម បណ្តោយដងខ្លួន ក្បាលវាពណ៌ខ្មៅ ។ ដង្កូវស៊ីរូងដើមឆ្នូត និងក្បាលខ្មៅ ចូលស៊ីក្នុងមួយដើមពី២-៥ ដង្កូវ ។ ដង្កូវញាស់ថ្មីៗផ្លាស់ទីទៅកាន់ដើមឬគុម្ពផ្សេងទៀត តាមរយៈសរសៃសូត្ររបស់វា ។ នៅពេលដង្កូវនៅតូច វាស៊ីនៅត្រង់ចន្លោះដើម និងស្រទាប់ស្លឹក ក្នុងរយៈពេល ២-៣ថ្ងៃមុនពេលវាចូលទៅក្នុងដើម ។ ដង្កូវចំណាស់ស៊ីនៅក្នុងដើមនៅជិតគល់ ហើយវាអាចស៊ីរូងចូលទៅក្រោមផ្ទៃដី នៅពេលដែលវាជិតក្លាយជាដឹកឌឿ ឬល័ក្ខខណ្ឌមិនសមស្របសម្រាប់វា ។

ដង្កូវក្លាយជាដឹកឌឿក្នុងដើមស្រូវនៅជិតគល់ ឬក្រោមផ្ទៃដី២-៣ សម។ មេអំបៅញាស់ពីសំបុកដឹកឌឿ រួចហើរចេញពីក្នុងដើមស្រូវតាមរន្ធដែលបានចោះទុក កាលវានៅជាដង្កូវ ។

## II. ការស៊ីបំផ្លាញ





វាស៊ីបំផ្លាញស្រូវ ដោយដង្កូវវាស៊ីរូងនៅក្នុងដើមស្រូវ ដែលអាចកាត់ផ្តាច់ចលនារបស់ទឹក និងជីជាតិ ។ វាបំផ្លាញស្រូវចាប់ពីដំណាក់កាលសំណាបរហូតដល់ស្រូវចេញផ្កា ។ ស្រូវស្វិតបណ្តូល នៅពេលដែលវាបំផ្លាញមុនពេលកកើតកួរ បណ្តូលដែលខូចខាតដោយសារដង្កូវស៊ីរូងដើម(ងាប់បណ្តូល) ងាយក្នុងការដកហូតចេញពីដើម ។ ជូនកាលនៅផ្នែកត្រង់គល់នៃស្លឹកដែលដកចេញមក គេសង្កេតឃើញមានកំទេចកំទី និងអាចម៍ដង្កូវ។ នៅពេលដែលវាបំផ្លាញក្រោយពេលកកើតកួរ គេសង្កេតឃើញកួរស ដែលបង្ហាញថាកួរស្រូវស្កកខូច។

## II. វិធានការការពារ និងកម្ចាត់

គេអាចការពារ និងកំចាត់វាដោយ :

- សំអាតស្មៅជុំវិញស្រែ
- ភ្ជួរស្រែបន្ទាប់ពីប្រមូលផល
- ដាំដុះឲ្យស្របពេលគ្នា
- កុំប្រើជីអាសូតច្រើនពេក ត្រូវប្រើឲ្យបានច្រើនដង
- ប្រើពូជធន់
- ប្រមូលសំបុកពងយកមកកម្ទេចចោល
- ថែរក្សាការពារសត្វមានប្រយោជន៍ ។